**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ៖ បព ១៦/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃទស្សនកិច្ចផ្លូវរដ្ឋរបស់ឯកឧត្តមបណ្ឌិត ថងលុន ស៊ីសុលីត អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ និងជាប្រធានរដ្ឋ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅព្រះរាជាណាចក្រកម្ពុជា

តបតាមការអញ្ជើញរបស់ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា **ឯកឧត្តមបណ្ឌិត ថងលុន ស៊ីសុលីត** អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ **និងជាប្រធានរដ្ឋ** នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី៦ ដល់ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៦។

ក្នុងអំឡុងពេលទស្សនកិច្ច **ឯកឧត្តមបណ្ឌិត ថងលុន ស៊ីសុលីត** មានជំនួបកំពូលជាមួយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងព្រះរាជបរមនាមជាប្រមុខរដ្ឋ។ **ឯកឧត្តមអគ្គលេខាធិការ** និងជា**ប្រធានរដ្ឋ** បានអញ្ជើញបំពាក់កម្រងផ្កា និងគោរពព្រះវិញ្ញាណក្ខន្ធ នៅវិមានឯករាជ្យ នៅមណ្ឌបព្រះបរមរូប **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ» អតីតព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា។

**សម្តេចតេជោ ហ៊ុន សែន** បានកោតសរសើរចំពោះសមិទ្ធផលសំខាន់ៗ ដែលរដ្ឋាភិបាល និងប្រជាជនឡាវសម្រេចបានក្នុងដំណើរការកសាងប្រទេស កំណែទម្រង់ និងការអភិវឌ្ឍ ក៏ដូចជាការសម្រេចបានដ៏គួរឱ្យកត់សម្គាល់នូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងកំណើនសេដ្ឋកិច្ចជាង៤% ក្នុងឆ្នាំ២០២៥។ **សម្តេចតេជោ** បានអបអរសាទរ **ឯកឧត្តមបណ្ឌិត ថងលុន ស៊ីសុលីត** យ៉ាងកក់ក្តៅ ចំពោះជោគជ័យនៃមហាសន្និបាតបក្សប្រជាជនបដិវត្តន៍ឡាវលើកទី១២ និងការជាប់ឆ្នោតសារជាថ្មីរបស់ **ឯកឧត្តម** ជាអគ្គលេខាធិការនៃគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ឡាវ សម្រាប់អាណត្តិទី២។ **សម្តេចតេជោ** បានជូនពររដ្ឋាភិបាល និងប្រជាជននៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឱ្យសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រចាំឆ្នាំជារៀងរាល់ឆ្នាំ ដើម្បីសម្រេចគោលដៅរយៈពេលវែង គឺក្លាយជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥៥ ស្របតាមចក្ខុវិស័យរបស់មហាសន្និបាតបក្សលើកទី១២។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

**ឯកឧត្តមបណ្ឌិត ថងលុន ស៊ីសុលីត** បានកោតសរសើរយ៉ាងខ្លាំងចំពោះសមិទ្ធផលដ៏លេចធ្លោ ដែលរាជរដ្ឋាភិបាលនិងប្រជាជនកម្ពុជាសម្រេចបាន ក្រោមព្រះរាជកិច្ចដឹកនាំដ៏ឈ្លាសវៃរបស់ **ព្រះករុណា ព្រះមហាក្សត្រ** និងការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេស ក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ **ឯកឧត្តមបណ្ឌិត** បានជូនពរមហាប្រសើរដល់ព្រះរាជាណាចក្រកម្ពុជាឱ្យទទួលបានជោគជ័យក្នុងការសម្រេចបានចក្ខុវិស័យវែងឆ្ងាយ ក្នុងការក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

**ថ្នាក់ដឹកនាំទាំងពីរ** បានសម្តែងនូវការពេញចិត្តចំពោះការរីកចម្រើនជាវិជ្ជមាន នៃទំនាក់ទំនងជិតស្និទ្ធ និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងកម្ពុជា និងឡាវ ក្នុងរយៈពេលកន្លងមកនេះដែលបាននាំមកនូវផលប្រយោជន៍រួមជាក់ស្តែងសម្រាប់ប្រជាជននៃប្រទេសទាំងពីរ។ ថ្នាក់ដឹកនាំទាំងសងខាងបានស្វាគមន៍ចំពោះការប្រាស្រ័យទាក់ទងគ្នាកម្រិតខ្ពស់ជាបន្តបន្ទាប់ និងទំនាក់ទំនងនៅគ្រប់កម្រិតលើគ្រប់វិស័យ ដែលបានពង្រឹងមិត្តភាពជាប្រពៃណីបន្ថែមទៀត និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីឱ្យកាន់តែមានអត្ថន័យ និងមានប្រសិទ្ធភាព។ ។

**ថ្នាក់ដឹកនាំទាំងពីរ** បានឯកភាពថា កម្ពុជា និងឡាវត្រូវរួមគ្នារៀបចំសកម្មភាពនានាឱ្យបានអធិកអធម ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧០ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរក្នុងឆ្នាំ២០២៦។ ទស្សនកិច្ចផ្លូវរដ្ឋរបស់**ឯកឧត្តមបណ្ឌិត ថងលុន ស៊ីសុលីត** នៅកម្ពុជានាពេលនេះ និងគម្រោងព្រះរាជទស្សនកិច្ចផ្លូវរដ្ឋរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** នៅឡាវនាពេលខាងមុខ គឺជាព្រឹត្តិការណ៍ដ៏សំខាន់ដើម្បីចូលរួមអបអរសាទរខួប៧០ឆ្នាំនេះ ។

ក្នុងបរិបទដែលសភាពការណ៍តំបន់ និងពិភពលោកកំពុងវិវត្តយ៉ាងឆាប់រហ័ស និងស្មុគស្មាញ ថ្នាក់ដឹកនាំទាំងពីរបានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការរឹតចំណងមិត្តភាពរវាងប្រទេសទាំងពីរឱ្យកាន់តែកក់ក្តៅ និងជិតស្និទ្ធថែមទៀត និងប្តេជ្ញាមិនអនុញ្ញាតឱ្យកម្លាំងអមិត្តណាមួយប្រើប្រាស់ទឹកដីរបស់ប្រទេសមួយ ដើម្បីបំផ្លាញសន្តិសុខ ស្ថិរភាព ឬអធិបតេយ្យរបស់ប្រទេសមួយទៀតឡើយ ស្របតាមស្មារតីមិត្តភាពជាប្រពៃណី សាមគ្គីភាព ភាពជាអ្នកជិតខាងល្អ និងទំនាក់ទំនងជាបងប្អូនយូរអង្វែងរវាងកម្ពុជា និងឡាវ ដើម្បីវិបុលភាពរួម ។

**ថ្នាក់ដឹកនាំទាំងពីរ** បានកោតសរសើរចំពោះកិច្ចសហការ និងការរក្សាបានសន្តិសុខតាមព្រំដែន ការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន សំដៅធ្វើឱ្យព្រំដែនយើងមានសុខសន្តិភាព និងបានឯកភាពបង្កើន និងពង្រឹងទំនាក់ទំនងរវាងកងកម្លាំងប្រដាប់អាវុធនៃប្រទេសទាំងពីរតាម រយៈការផ្លាស់ប្តូរនទពិសោធន៍ ដើម្បីចូលរួមចំណែកឆ្លើយតបទៅនឹងតម្រូវការក្នុងបរិបទបច្ចុប្បន្ន ព្រមទាំងពង្រឹងយន្តការយោធាក្នុងក្របខ័ណ្ឌបីប្រទេសកម្ពុជា-ឡាវ-វៀតណាម ។

**ថ្នាក់ដឹកនាំទាំងពីរ** វាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលនៃប្រទេសទាំងពីរក្នុងការសម្រេចបានការងារខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនបាន៨៦% និងបានឯកភាពរួមគ្នា ដោះស្រាយបញ្ហាព្រំដែនដែលនៅសេសសល់ប្រមាណ១៤% ដើម្បីប្រែក្លាយតំបន់ព្រំដែនជាព្រំដែន មិត្តភាព សន្តិភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍសម្រាប់ផលប្រយោជន៍នៃប្រជាជនទាំងពីរ។

**ថ្នាក់ដឹកនាំទាំងពីរ** បានកត់សម្គាល់ដោយពេញចិត្តចំពោះការវិវត្តប្រកបដោយផ្លែផ្កានៃកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មរវាងកម្ពុជានិងឡាវ និងបានទទួលស្គាល់ពីសក្តានុពលសំខាន់ៗសម្រាប់ការពង្រីកពាណិជ្ជកម្មទ្វេភាគី និងលើកកម្ពស់ទំនាក់ទំនងធុរកិច្ច និងបានលើកទឹកចិត្តឱ្យអាជ្ញាធរពាក់ព័ន្ធនៃប្រទេសទាំងពីរសហការគ្នាជំរុញទំហំពាណិជ្ជកម្មឱ្យឈានដល់គោលដៅ ៧០០ លានដុល្លារអាមេរិក ត្រឹមឆ្នាំ២០៣០។

**ថ្នាក់ដឹកនាំទាំងពីរ** បានយកចិត្តទុកដាក់ខ្ពស់ចំពោះការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរវាងប្រទេសទាំងពីររួមទាំងការសាងសង់ស្ពានឆ្លងកាត់ទន្លេរពៅ(កម្ពុជា)/ សេឡាំផាវ (ឡាវ) និងបានអបអរសាទរការចុះហត្ថលេខាកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនកសិផលឆ្លងកាត់ប្រទេសឡាវរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកម្ពុជា និងក្រសួងកសិកម្ម និងបរិស្ថានឡាវ កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៦។

**ថ្នាក់ដឹកនាំទាំងពីរ** បានឯកភាពបន្តពង្រឹង និងបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យថាមពលតាមរយៈការអនុវត្តកិច្ចព្រមព្រៀង និងអនុស្សរណៈនានា ពាក់ព័ន្ធនឹងថាមពល ឱ្យបានសកម្ម និងមានប្រសិទ្ធភាពខ្ពស់។

**ថ្នាក់ដឹកនាំទាំងពីរ** បានកោតសរសើរចំពោះកិច្ចសហប្រតិបត្តិការអភិវឌ្ឍធនធានមនុស្ស រវាងប្រទេសយើងទាំងពីរ ជាពិសេស ការបន្តផ្តល់អាហារូបករណ៍ និងវគ្គបណ្តុះបណ្តាលដល់និស្សិត និងមន្ត្រីទៅវិញទៅមក។ ថ្នាក់ដឹកនាំទាំងពីរក៏បានសម្តែងក្តីរីករាយផងដែរ ដែលរដ្ឋាភិបាលទាំងពីរបានយកចិត្តទុកដាក់មើលថែ និងផ្តល់ការសម្របសម្រួលដល់សិស្សនិស្សិតកម្ពុជា និងឡាវ ក្នុងប្រទេសនីមួយៗ។

ក្នុងបរិយាកាសកក់ក្តៅ និងមិត្តភាពដ៏ជ្រាលជ្រៅ **ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ** បានពិភាក្សាត្រង់ទៅត្រង់មកអំពីកិច្ចសហប្រតិបត្តិការលើវិស័យនានារួមទាំង ទេសចរណ៍ វប្បធម៌ ការផ្លាស់ប្តូរប្រជាជននិងប្រជាជន និងបានផ្លាស់ប្តូរទស្សនៈលើបញ្ហាសន្តិសុខតំបន់ និងអន្តរជាតិ ដែលជាការយកចិត្តទុកដាក់រួម។

**ឯកឧត្តមបណ្ឌិត ថងលុន ស៊ីសុលីត** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ដែលបានអញ្ជើញ **ឯកឧត្តម** មកបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជា និងចំពោះថ្នាក់ដឹកនាំ និងប្រជាជនកម្ពុជាដែលបានផ្តល់បដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅជូនគណៈប្រតិភូជាន់ខ្ពស់ឡាវ។ **ឯកឧត្តម** ទន្ទឹងរង់ចាំទទួលបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ យាងបំពេញព្រះរាជទស្សនកិច្ចផ្លូវរដ្ឋ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវនាពេលខាងមុខ។

ថ្ងៃសៅរ៍ ៥កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ២០២៦